គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## វគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់នាយនគរបាលជាន់ខ្ពស់ និងមន្ត្រីក្រោមឱវាទ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ៨ និង ០០ នាទី នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់នាយនគរបាលជាន់ខ្ពស់ និងមន្ត្រីក្រោមឱវាទ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី **លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ និង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាគ្រូឧទ្ទេស ចំនួន ១៦ រូប និងមានការចូលរួមពីសិក្ខាកាម ជានាយនគរបាលជាន់ខ្ពស់ និងមន្ត្រីក្រោមឱវាទ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ៣៥ រូប ស្រី ០៥ រូប ។

កម្មវិធីបណ្តុះបណ្តាលជំនាញ លើការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានលើកមកបង្ហាញ និងធ្វើការពន្យល់ពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាគ្រូឧទ្ទេស ទាំង១៦ រូប ធ្វើការបែងចែកមេរៀនទៅតាមជំនាញផ្សេងៗគ្នា ដើម្បីធ្វើការបណ្តុះបណ្តាលរយៈពេល ០១ថ្ងៃកន្លះ ចាប់ពីថ្ងៃព្រហស្បតិ៍ ទី១៦ ពេលព្រឹក និងបានបញ្ចប់នៅថ្ងៃសុក្រ ទី១៧ ខែកញ្ញា ឆ្នាំ២០២១ ពេលថ្ងៃ ដោយមានគ្រូឧទ្ទេស និងមេរៀនបណ្តុះបណ្តាលតាមជំនាញនីមួយៗដូចខាងក្រោម៖

១.ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ូ ម៉ានីរ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ (មេរៀន៖ គោលដៅ គោលបំណង និងសេចក្តីផ្តើម)

២.លោក ឧត្តមសេនីយ៍ទោ សេក ស៊ីវ៉េត ប្រធានក្រុមជំនួយកិច្ចការ ការពារជនរងគ្រោះ (មេរៀន៖ ការណែនាំ និងសារសំខាន់ នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស)

៣.លោក អនុសេនីយ៍ឯក រ៉ន សុភ័ក្រ្តបញ្ញា មន្ត្រីលេខាធិការដ្ឋានរដ្ឋបាលសរុប នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ(មេរៀន៖ អ្នកមានសមត្ថកិច្ចដំណាក់កាល នៃការកំណត់អត្តសញ្ញាណ និងការជួបដំបូង)

៤.លោក អនុសេនីយ៍ឯក ហង្ស ពុទ្ធារិទ្ធ នាយរងការិយាល័យសរុបផែនការ (មេរៀន៖ ការត្រៀមសម្ភាសន៍ និងការសម្ភាសជាផ្លូវការ)

៥.លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ (មេរៀន៖ ជាតុផ្សំ នៃបទល្មើសជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ករណីអនីតិជន ដំណាក់កាលទាំងបី)

៦.លោក ឧត្តមសេនីយ៍ទោ កែវ ផល្លា ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ (មេរៀនៈ និយមន័យ «ជនរងគ្រោះ» លក្ខណៈសំគាល់ជនរងគ្រោះ)

៧.ឯកឧត្តម ឧត្តមសេនីយ៍ឯក លី តុងហ៊ុយ អគ្គលេខាធិការរង គ.ជ.ប.ជ (មេរៀនៈ លក្ខណៈសំគាល់ជនរងគ្រោះ និងការកំណត់អាយុជនរងគ្រោះ វិធានការ៦ចំណុច)

៨.ឯកឧត្តម ឧត្តមសេនីយ៍ទោ នី គឹមស្រេន អគ្គលេខាធិការរង គ.ជ.ប.ជ (មេរៀនៈ វិធីសាស្ត្រនិងទម្រង់បែបបទសម្ភាសន៍ ទម្រង់ខ្លី សារសំខាន់ផ្នែកផ្សេងៗនៃទម្រង់ខ្លី)

៩.លោកស្រី វរសេនីយ៍ត្រី ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ (មេរៀនៈ ទម្រង់វែង ផ្នែកផ្សេងៗនៃទម្រង់វែង)

១០.លោក ឧត្តមទោ រ៉ន សុភ័ក្ត្រវឌ្ឍនា ប្រធានក្រុមជំនួយកិច្ចបង្ការទប់ស្កាត់ (មេរៀនៈ របៀបវិភាគសន្និដ្ឋាន ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ)

១១.លោក អនុសេនីយ៍ឯក សោម ស៊ីវីន នាយរងការិយាល័យស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ (មេរៀនៈ កំណត់សំគាល់ ទម្រង់ស្នើសុំសម្ភាសន៍)

១២.លោក អនុសេនីយ៍ឯក នន់ ឧត្តម នាយរងការិយាល័យផ្សព្វផ្សាយ អប់រំ (មេរៀនៈ សិទ្ធិជនរងគ្រោះ ការផ្តល់សេវាជូនជនរងគ្រោះ សេវាបឋម (សេវាសង្គ្រោះបន្ទាន់ សេវាចាំបាច់ជាមូលដ្ឋាន)

១៣.ឯកឧត្តម ឧត្តមសេនីយ៍ត្រី តែ សុថារ៉េត អគ្គលេខាធិការរង គ.ជ.ប.ជ (មេរៀនៈ សេវាបន្ត វិធានការ៦ចំណុច)

១៤.លោក ឧត្តមសេនីយ៍ត្រី អ៊ិន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ (មេរៀនៈ វិធានការសំខាន់ៗ ក្រោយពេលកំណត់អត្តសញ្ញាណ ករណីជនរងគ្រោះកម្ពុជានៅបរទេស ករណីជនបរទេសនៅកម្ពុជា គំនូសបំព្រួញ នៃប្រព័ន្ធបញ្ជូន)

១៥.ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ សុវណ្ណារ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ (មេរៀនៈ តួនាទី និងភារកិច្ចនគរបាលយុត្តិធម៌ មន្ត្រីសង្គមកិច្ច អ្នកផ្តល់សេវាបន្ត(អង្គការដៃគូ)

១៦.លោក ឧត្តមសេនីយ៍ទោ ស្រី សាមឌី ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ (មេរៀនៈ តួនាទីទីភ្នាក់ងារជ្រើសរើសពលករ ស្ថានទូតឬស្ថានតំណាងនៅប្រទេសគោលដៅ)

**លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ និងបញ្ជាក់បន្ថែមអំពីចំណុចសំខាន់ៗ នៃមេរៀនទាំងអស់ដែលបានលើកមកបង្ហាញ និងពន្យល់ដោយគ្រូឧទ្ទេស ដល់នាយនគរបាលជាន់ខ្ពស់ និងមន្ត្រីក្រោមឱវាទ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលបានចូលរួមវគ្គបណ្តុះបណ្តាលនេះ ។ **លោកជំទាវ** មានប្រសាសន៍ណែនាំបន្ថែមដល់នាយនគរបាលជាន់ខ្ពស់ និងមន្ត្រីទាំងអស់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ត្រូវយល់អំពីសារៈសំខាន់ នៃការងារ ត្រូវចូលរួមសហការបំពេញការងារ ត្រូវយល់ដឹងអំពីតួនាទីភារកិច្ចរបស់ខ្លួននៅក្នុងអង្គភាព ត្រូវត្រៀមខ្លួនជានិច្ច ដើម្បីអនុវត្តការងារនៅក្នុងអង្គភាព ការងារយើងមានច្រើនដែលត្រូវរួមគ្នាធ្វើ ត្រូវបែងចែក និងអនុវត្តការងារឲ្យបានច្បាស់លាស់ ព្រោះយើងគឺជាក្រុមការងារថ្នាក់ជាតិ ។

**លោកជំទាវ** បានមានប្រសាសន៍ថ្លែងអំណរគុណ និងជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រីជាគ្រូឧទ្ទេស និងលោក លោកស្រីជាថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទទាំងអស់ដែលបានចូលរួមវគ្គបណ្តុះបណ្តាលនេះ សូមជួបតែសេចក្តីសុខ ជៀសផុតពីជំងឺទាំងឡាយ និងទទួលបានជោគជ័យគ្រប់ភារកិច្ច ។

ថ្ងៃចន្ទ ១៤កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១
**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ទោ. សៅ ស៊ីនួន

**សូមគោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់
ថ្ងៃចន្ទ ១៤កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណ សំខាន់

បានឃើញ
22/09/21